**សហគមន៍ខ្មែរកម្ពុជាក្រោម**
**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ..............................ស.ខ.ក.ក.

# សារជូនពរ

## ឯកឧត្តម ថាច់ សេដ្ឋា សមាជិកព្រឹទ្ធសភា
## និងជានាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម
## ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនជនរួមឈាមខ្មែរកម្ពុជាក្រោម
## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !

សូមគោរពជនរួមឈាមជាទីស្នេហា !

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរោងចត្វាស័កព.ស.២៥៥៦នេះ ក្នុងនាមថ្នាក់ដឹកនាំសហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំសូមចូលរួមអបអរសាទររីករាយសប្បាយទទួលទេវតាឆ្នាំថ្មី ជាមួយព្រះកុណាគ្រប់ព្រះអង្គ និងជនរួមឈាម ដោយសេចក្តីស្រឡាញ់និងស្មោះត្រង់ជាទីបំផុត។ ជាមួយគ្នានេះ ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរ ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជូនបងប្អូនជនរួមឈាមទាំងអស់ បានប្រកបដោយសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គលគ្រប់ៗក្រុមគ្រួសារ និងទទួលបាននូវសិទ្ធិសេរីភាពពេញលេញក្នុងឋានៈជាម្ចាស់នៃទឹកដីកម្ពុជាក្រោម កុំបីខាន។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ !

បងប្អូនជនរួមឈាមជាទីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត !

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវការគោរព និងកោតសសើរដោយស្មោះអស់ពីដួងចិត្ត ចំពោះព្រះថេរានុត្ថេរៈគ្រប់អង្គ និងបងប្អូនរួមឈាមទាំងអស់ ដែលបានការពារ ថែរក្សា និងគោរពយ៉ាងខ្ជាប់ខ្ជួននូវប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ដ៏ល្អផូរផង់នៃប្រជាជាតិខ្មែរយើង។ នេះជាការឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់នូវមនសិការស្នេហាជាតិរបស់ព្រះករុណាគ្រប់ព្រះអង្គ និងជនរួមឈាមដ៏ពិតប្រាកដ។ ខ្ញុំព្រះករុណាខ្ញុំ នៅចាំបានថាគ្រប់ពេលនៃឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនៅលើទឹកដីកម្ពុជាក្រោម ប្រជារាស្ត្រខ្មែរបានរៀបចំគ្រឿងសក្ការៈបូជា ដើម្បីអបអរសាទរទទួលទេវតាឆ្នាំថ្មីនៅគ្រប់លំនៅឋាន។ នៅតាមវត្តអារាមនានា ពុទ្ធបរិសទ័នៅគ្រប់ទិសទីបានមកជួបជុំគ្នាយ៉ាងច្រើនកុះករ វេរចង្ហាន់ប្រគេនព្រះសង្ឃ ដើម្បីជារបង្សុក្កូល ឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធបុព្វការីជន និងព្រះវិញ្ញាណក្ខន្ធវីរសមណៈ និងវិញ្ញាណក្ខន្ធវីរបុរសព្រមទាំងស្តាប់ព្រះសង្ឃសម្តែងព្រះធម្មវិសេសទេសនាអំពីរឿងព្រះវេស្សន្តរជាតក ឬមង្គលសូត្រចំនួនបីយប់បីថ្ងៃមិនដែលខកខានម្តងឡើយ។ ម្យ៉ាងទៀតចំពោះបងប្អូនរួមឈាមនៅឯនាយសមុទ្រឯណោះវិញ ក៏មានស្មារតីមិនខុសពីបងប្អូនរួមឈាមនៅឯមាតុភូមិ

កម្ពុជាក្រោមនោះដែរ ទោះបីមានភ័ព្វវាសនាបានទៅរស់នៅលើទឹកដី ដែលពោរពេញទៅដោយសេរីភាព និងសម្បូណ៍បែបយ៉ាងណាក៏ដោយ ក៏មិនដែលបោះបង់ចោលឧត្តមគតិស្នេហាជាតិ មាតុភូមិរបស់ខ្លួនម្តងណាឡើយ នៅតែបន្តការតស៊ូ ដោយបានចូលរួមគ្រប់សកម្មភាព ដែលជាឧត្តមប្រយោជន៍ប្រជារាស្ត្រ និងមាតុភូមិកម្ពុជាក្រោមជានិច្ច។

ខ្ញុំព្រះកុណាខ្ញុំ សូមព្រះអនុញ្ញាត និងអនុញ្ញាតទូលប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិព្រះមេត្តា និងមេត្តាជ្រាបថា ភាពគង់វង្សពូជសាសន៍ ទំនៀមទម្លាប់ ប្រពៃណី សីល្បៈ វប្បធម៌ អក្សរសាស្ត្រ ព្រះពុទ្ធសាសនាខ្មែរ ដែលយើងបានឃើញនៅមានជីវិតរស់រវើកនៅលើទឹកដីកម្ពុជាក្រោមសព្វថ្ងៃ មិនមែនដោយសារការប្រទាន ដោយមេត្តាធម៌ ឬការអាណិតអាសូររបស់អាជ្ញាធរអាណានិគមវៀតណាមនោះទេ គឺបានមកដោយការតស៊ូពលីជីវិត សាច់ស្រស់ឈាមស្រស់របស់កុលបុត្រកុលធីតាខ្មែរស្នេហាជាតិនៅគ្រប់សម័យកាល។ ដូចនេះ យើងជាខេមរកុលបុត្រគ្រប់រូបត្រូវតែបន្តវេននៃការតស៊ូពីវីរបុរសរបស់យើងជាបន្តទៀត រហូតទទួលបានសិទ្ធិសេរីភាពពេញលេញក្នុងឋានៈយើងជាម្ចាស់ដើមនៃទឹកដីកម្ពុជាក្រោមយ៉ាងពិតប្រាកដ។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវយ៉ាងទទូចដល់បងប្អូនរួមឈាមជាទីស្នេហាថា អ្វីដែលជាការថ្នាក់ថ្នាំងចិត្តដែលជាហេតុនាំឲ្យមានមន្ទិលសៅហ្មងរវាងគ្នានិងគ្នានៅក្នុងឆ្នាំចាស់ទាំងអម្បាលម៉ាន សូមមេត្តាបំភ្លេចចោលជាអហោសិកម្មទៅតាមឆ្នាំចាស់ឲ្យអស់ កុំបីមានសេសសល់នៅក្នុងខន្ធសន្តានរបស់យើងឡើយ ហើយសូមងាកមករួបរួមសាមគ្គីគ្នាជាធ្លុងមួយក្នុងមហាគ្រួសារខ្មែរកម្ពុជាក្រោម ដើម្បីជំរុញចលនាតស៊ូរបស់យើងឲ្យបានដល់គោលដៅយ៉ាងឆាប់រហ័សបំផុតក្នុងការជួយស្រោចស្រង់ប្រជារាស្ត្រ និងមាតុភូមិកម្ពុជាក្រោមរបស់យើង។ មានន័យថា សូមមេត្តាតម្កល់ផលប្រយោជន៍ជាតិជាធំ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមបួងសួងគុណបុណ្យព្រះរតនត្រៃ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ ជាពិសេស ទេវតារក្សាឆ្នាំថ្មី ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦ គ.ស.២០១២ សូមជួយបីបាច់ថែរក្សាព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមគ្រប់រូបឲ្យទទួលបាននូវសិទ្ធិសេរីភាពពេញលេញដូចមនុស្សជាតិនានានៅលើសកលលោក និងសូមឲ្យទទួលបាននូវពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមឈាមទាំអស់ ព្រះមេត្តា និងមេត្តាទទួលនូវការគោរពនិងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំព្រះករុណាខ្ញុំ៕

*រាជធានីភ្នំពេញ ថ្ងៃពុធ ០៥រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១១ ខែមេសា ព.ស.២៥៥៦ គ.ស.២០១២*

សូមអរព្រះគុណ និងអរគុណ!

THE KHMER KAMPUCHEA KROM COMMUNITY